សម្ព័ន្ធភាពជាតិឃុំ សង្កាត់
នៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ស្តីពី
# សមិទ្ធផលរបស់សម្ព័ន្ធភាពជាតិឃុំ សង្កាត់ និងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត និងរាជធានី

## I. សមិទ្ធផល

ទស្សនាទាននៃការបង្កើតសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានពិភាក្សាជាមួយប្រតិភូក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានអញ្ជើញចូលរួមនៅក្នុងសន្និបាតក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសលើកទីមួយនៅក្រសួងមហាផ្ទៃ នាថ្ងៃទី៧-៩ ខែមេសា ឆ្នាំ២០០៣។ ប្រតិភូក្រុមប្រឹក្សាឃុំ សង្កាត់ បានឯកភាពទស្សនាទាននេះ ហើយបានសំដែងការប្តេជ្ញាចិត្តក្នុងការរៀបចំបង្កើតសមាគមឲ្យទទួលបានជោគជ័យ។ ជាមួយគ្នានេះ នៅក្នុងឱកាសបិទសន្និបាត សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសំដែងក្តីសោមនស្សរីករាយ ដោយសម្តេចបានជ្រាបថា នៅក្នុងសន្និបាតនេះ មានការពិគ្រោះពិភាក្សា និងការប្រមូលគំនិតនានាអំពីការបង្កើតសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅព្រះរាជាណាចក្រកម្ពុជា។ សម្តេច បានចាត់ទុកថា សមាគមនេះ នឹងដើរតួនាទី និងជាដៃគូយ៉ាងសំខាន់នៅក្នុងការជំរុញដំណើរការវិមជ្ឈការ និងការអនុវត្តអភិបាលកិច្ចមូលដ្ឋាន។ នៅក្នុងការរៀបចំបង្កើតសមាគម សម្តេច បានណែនាំឲ្យយកចិត្តទុកដាក់ផ្សារភ្ជាប់លក្ខណៈជាក់ស្តែងនៅកម្ពុជា ហើយត្រូវមានទិសដៅច្បាស់លាស់ មានការទទួលខុសត្រូវ និងត្រូវធ្វើការថ្លឹងថ្លែងអំពីសមត្ថភាពរបស់សមាគមផងដែរ ។

ផ្អែកតាមស្មារតីនៃសន្និបាតនេះ គណៈកម្មាធិការបណ្តោះអាសន្ន ដែលមានសមាជិក ១៩៨ នាក់ និងក្រុមការងារថ្នាក់ជាតិដែលមានសមាជិក ៥២ នាក់ ត្រូវបានបង្កើតឡើង។ គណៈកម្មាធិការ និងក្រុមការងារមានភារកិច្ចរៀបចំសេចក្តីព្រាងលក្ខន្តិកៈរបស់សម្ព័ន្ធភាពជាតិ និងសមាគមប្រឹក្សានៅតាមខេត្ត និងរាជធានីភ្នំពេញ ក៏ដូចជារៀបចំឯកសារបច្ចេកទេស និងផែនការការងារ ដើម្បីជម្រុញការផ្សព្វផ្សាយ និងការបង្កើតសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត និងរាជធានីភ្នំពេញ។ ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីក្រុមការងាររបស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ នាថ្ងៃ២២ខែធ្នូ ឆ្នាំ២០០៥ សមាគមក្រុមប្រឹក្សាសង្កាត់ ត្រូវបាន

ស្ថិតក្នុងបរិវេណព្រឹទ្ធសភា មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ (៨៥៥ ២៣) ៧២៦ ២៥៩, ទូរសារ ៖ (៨៥៥ ២៣) ៧២៦ ២៥៩
អ៊ីមែល ៖ nlc.s@online.com.kh វេបសាយត៍៖ www.nlcs.org.kh

ឆ្លើយតបនឹងតម្រូវការជាបន្ទាន់របស់ប្រជាពលរដ្ឋនៅមូលដ្ឋានដែលជាម្ចាស់ឆ្នោត។ នៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាឃុំ សង្កាត់ជួបប្រទះបញ្ហាប្រឈមមួយចំនួនដែលទាមទារឲ្យមានដំណោះស្រាយសមស្រប។ ក្នុងន័យនេះ សម្ព័ន្ធភាពជាតិ បាន និងកំពុងគាំទ្រសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត និងរាជធានី ដើម្បីរៀបចំវេទិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមក្រុង ស្រុក និងខណ្ឌ។ គណៈអភិបាលស្រុក រួមជាមួយនឹងតំណាងការិយាល័យរបស់ក្រសួង ស្ថាប័ន បានចូលរួមនៅក្នុងវេទិកានេះ ដើម្បីស្តាប់បញ្ហាប្រឈម និងសំណូមពរផ្សេងៗ ដែលបានលើកឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយរួមគ្នាស្វែងរកដំណោះស្រាយដែលមានលក្ខណៈសមស្របនៅមូលដ្ឋាន។ ជាមួយគ្នានេះ សម្ព័ន្ធភាពជាតិ បានសហការជាមួយស្ថាប័នព្រឹទ្ធសភា ដើម្បីរៀបចំវេទិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមភូមិភាគទាំង ៨ របស់ព្រឹទ្ធសភាប្រកបដោយជោគជ័យ។ តាមរយៈវេទិកានេះ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានឱកាសដ៏ល្អដើម្បីជម្រាបជូនសមាជិកព្រឹទ្ធសភា និងតំណាងក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធចំបងនៅក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការអំពីបញ្ហានានាដែលឃុំ សង្កាត់កំពុងជួបប្រទះ និងលើកសំណូមពរ ដើម្បីដោះស្រាយ និងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់។ បន្ទាប់ពីការរៀបចំវេទិកានៅតាមភូមិភាគទាំង ៨ សម្ព័ន្ធភាពជាតិឃុំ សង្កាត់ បានរៀបចំបញ្ជីបញ្ហាប្រឈមដែលបានលើកឡើងនៅក្នុងវេទិកា ហើយបានផ្ញើជូនក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកិច្ចការនារី និងក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីស្នើសុំអន្តរាគមន៍ដោះស្រាយ។ ជាមួយគ្នានេះដែរ សម្ព័ន្ធភាពជាតិ បានរៀបចំវេទិកានៅតាមខេត្ត និងរាជធានីទាំង ២៤ ដើម្បីធ្វើការអង្កេតអំពីការទទួលខុសត្រូវ សមត្ថភាព និងការបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ សង្កាត់។ របាយការណ៍នៃការអង្កេតនេះ ត្រូវបានរៀបចំរួចរាល់ ហើយត្រូវបានចែកជូនប្រតិភូចូលរួមនៅក្នុងសន្និបាតបូកសរុបសមិទ្ធផលការងារក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២។

<u>**ទីបី**</u>៖ ការចូលរួមជាសំលេងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងយន្តការផ្សេងៗ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដើម្បីបានទទួល និងពិចារណាមតិយោបល់ និងសំណូមពរផ្សេងៗ របស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាអ្នកដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា រាជរដ្ឋាភិបាលបានកំណត់ឲ្យមានតំណាងរបស់សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត និងរាជធានីនៅក្នុងយន្តការនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មានជាអាទិ៍ក្រុមការងារគណនេយ្យភាពខេត្ត និងរាជធានីភ្នំពេញ គណៈកម្មា-

លើកឡើងពីសំណូមពរឱ្យតំឡើងប្រាក់ឧបត្ថម្ភ និងការផ្តល់សម្លៀកបំពាក់ឯកសណ្ឋាន និងសញ្ញាស័ក្តិសំគាល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។ ផ្អែកលើសំណូមពរទាំងនេះ សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានផ្ញើលិខិតលេខ ១៥៨/០៦១០/ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១០ ជូនឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយស្នើសុំបង្កើនប្រាក់បំណាច់ប្រចាំខែជូនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ ដោយមានអន្តរាគមន៍ពីឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០១០ កំណត់ប្រាក់ឧបត្ថម្ភសំរាប់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និងជាមេឃុំ ចៅសង្កាត់ចំនួន ១៥០.០០០រៀល ក្នុងមួយខែ សមាជិកក្រុមប្រឹក្សាដែលទទួលមុខតំណែងជាជំទប់ទីមួយ និងជំទប់ទីពីរ ចៅសង្កាត់រងទីមួយ ចៅសង្កាត់រងទីពីរចំនួន ១២០.០០០ រៀល ក្នុងមួយខែ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ធម្មតាចំនួន ១០០.០០០រៀល ក្នុងមួយខែ មេភូមិ ៦០.០០០រៀលក្នុងមួយខែ អនុប្រធានភូមិ ៥០.០០០រៀល ក្នុងមួយខែ និងសមាជិកភូមិ ៤០.០០០រៀលក្នុងមួយខែ។ ប្រាក់ឧបត្ថម្ភថ្មីនេះ ត្រូវបានអនុវត្តចាប់ពីខែមករា ឆ្នាំ២០១១ តទៅ។ ជាមួយគ្នានេះដែរ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ កម្ពុជា បានចុះហត្ថលេខាលើអនុក្រឹត្យ លេខ ៦២ អនក្រ បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១១ ស្តីពីឯកសណ្ឋានការងារ និងសញ្ញាស័ក្តិសម្រាប់សម្គាល់មេឃុំ ចៅសង្កាត់ ជំទប់ឃុំ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាឯកសណ្ឋានការងារ និងសញ្ញាស័ក្តិត្រូវផ្តល់ដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាលើកដំបូងនៅកម្ពុជា។

**ទីប្រាំពីរ៖** ការចូលរួមនៅក្នុងយន្តការអន្តរជាតិ។ បន្ទាប់ពីត្រូវបានចាប់បដិសន្ធិ សម្ព័ន្ធភាពជាតិ បានចូលជាសមាជិកពេញសិទ្ធិរបស់សមាគមអាជ្ញាធរមូលដ្ឋានពិភពលោក និងប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (World UCLG និងUCLG ASPAC) ព្រមទាំងជាសមាជិកគណៈកម្មាធិការពិគ្រោះយោបល់ការងាររឹមជ្ឈការ និងវិសហមជ្ឈការដែលមានមូលដ្ឋាននៅទីក្រុងបាសេឡូណា ប្រទេសអេស្ប៉ាញ ក្នុងគោលបំណងចែករំលែកពិសោធន៍ការងារសមាគម ចំណេះដឹងអភិបាលកិច្ចមូលដ្ឋាន និងជំនាញផ្សេងៗទៀត។ សម្ព័ន្ធភាពជាតិ ជាសមាជិកមួយនៃគម្រោងភាពជាដៃគូទីក្រុងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដែលមានប្រទេសចំនួន៧ ទៀតជាសមាជិកក្រោមការគាំទ្រផ្នែកហិរញ្ញវត្ថុពីទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិនៃប្រទេសកាណាដា(CIDA)តាមរយៈសហព័ន្ធទីក្រុងនៃប្រទេសកាណាដា និងជាសមាជិកគម្រោងភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យនៅអាស៊ីអាគ្នេយ៍ ដែលមានប្រទេសចំនួន ៥ ទៀតនៅក្នុងតំបន់ជាសមាជិកក្រោមការគាំទ្រផ្នែកហិរញ្ញវត្ថុពីសហ-ភាពអឺរ៉ុប តាមរយៈមូលនិធិខុនរាឌ អាដេនុអែរ។ ជាមួយ

- សម្ព័ន្ធភាពជាតិឃុំ សង្កាត់ជាស្ថាប័នថ្មី ដូច្នេះក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ មិនស្គាល់សម្ព័ន្ធភាពជាតិឃុំ សង្កាត់បានទូលំទូលាយ។
- សមាគមក្រុមប្រឹក្សាឃុំ សង្កាត់ មួយចំនួនមិនទាន់មានការិយាល័យ ហើយមានការខ្វះខាតសំភារៈ ការិយាល័យសម្រាប់បំពេញការងារប្រចាំថ្ងៃរបស់ខ្លួន។
- ការផ្សព្វផ្សាយ និងការប្រមូលព័ត៌មានពីសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ មិនទាន់មានលក្ខណៈទូលំទូលាយនៅឡើយ។
- ដៃគូអភិវឌ្ឍន៍ផ្តោតការយកចិត្តទុកដាក់នៃការផ្តល់ជំនួយរបស់ខ្លួនទៅលើការអនុវត្តសកម្មភាព ហើយមិនសូវគិតពីការគាំទ្រទៅលើផ្នែកបុគ្គលិក និងប្រតិបត្តិការ។ ប្រការនេះធ្វើឲ្យសម្ព័ន្ធភាពជាតិជួបការលំបាកជាខ្លាំងក្នុងការស្វែងរកធនធានសំរាប់ទ្រទ្រង់ការចំណាយលើផ្នែកទាំងនេះ ។

## III. **ទិសដៅអនុវត្តបន្ត**

- អនុវត្តអនុកម្មវិធីទី ៦ នៃ ផអ៣ ដែលផ្តោតទៅលើការកសាងពង្រឹងសមត្ថភាពសម្ព័ន្ធភាពជាតិឃុំ សង្កាត់ និងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមខេត្ត និងរាជធានី។
- បន្តពង្រឹងសមត្ថភាពសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការផ្តល់សេវាដល់សមាជិករបស់ខ្លួន
- ធ្វើការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាក្រុង ស្រុក និងខណ្ឌ អំពីការធ្វើសមាហរណកម្មក្រុមប្រឹក្សានេះចូលក្នុងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ និងសម្ព័ន្ធភាពជាតិឃុំ សង្កាត់ បន្ទាប់ពីបានទទួលអនុសាសន៍ពីរាជរដ្ឋាភិបាល
- រៀបចំសន្និបាតសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ដើម្បីជ្រើសរើសរចនាសម្ព័ន្ធដឹកនាំថ្មី បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់សម្រាប់អាណត្តិទីបីនៅឆ្នាំ ២០១២។
- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍
- អនុវត្តសកម្មភាពនៅក្នុងផែនការយុទ្ធសាស្ត្ររបស់សម្ព័ន្ធភាពជាតិរយៈពេល ៥ ឆ្នាំ (២០១១-២០១៥)។




ស្ថិតក្នុងបរិវេណព្រឹទ្ធសភា មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ (៨៥៥ ២៣) ៧២៦ ២៥៤, ទូរសារ ៖ (៨៥៥ ២៣) ៧២៦ ២៥៤
អ៊ីមែល ៖ nlc.s@online.com.kh     វេបសាយត៍៖ www.nlcs.org.kh